អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ
Cambodian Ministries for Christ International
Address: # 25B, St. 578, Beong kok II, Toul Kork, Phnom Penh, Cambodia.
Tel: 012 856 100. E-mail: t_bunsoeum@cmc news.org

# របាយការណ៍ស្តីអំពីសកម្មភាពផ្សេងៗ
# ចាប់ពីខែ មេសា ដល់ ខែ មិថុនា ឆ្នាំ២០០៧

## I-ផ្នែកសាងសង់:

*យើងបានចាប់ផ្តើមសាងសង់ថ្មីចំនួន២ខ្នងទៀតគឺ*

១-សាងសង់ព្រះវិហារថ្មីនៅភូមិ រកាលើ ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ដែលមានទទឹង ៨ម៉ែត្រ បណ្តោយ ២០ម៉ែត្រធ្វើអំពីថ្ម ចំណាយអស់ទឹកប្រាក់ចំនួន$១៨៥០០។






២-ចាប់ផ្តើមសាងសង់ព្រះវិហារថ្មីនៅភូមិ ស្រះកែវ ឃុំ មេលំ  ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង ដែលមានទទឹង ៨ម៉ែត្រ បណ្តោយ ២០ម៉ែត្រធ្វើអំពីថ្ម ចំណាយអស់ទឹកប្រាក់ចំនួន$១៨៥០០។






## II-ផ្នែកសិក្សាអប់រំ:

វិទ្យាស្ថានព្រះគម្ពីរអភិវឌ្ឍន៍អ្នកដឹកនាំបានហ្វឹកហ្វឺនដល់គ្រូគង្វាលនិងអ្នកដឹកនាំ ចំនួន៨៩៨ នាក់នៅក្នុងខេត្ត/ក្រុងចំនួន៩ នៃព្រះរាជាណាចក្រកម្ពុជា គឺ:-

១-រាជធានីភ្នំពេញ មាននិស្សិតចំនួន៥៧ នាក់

២-ខេត្តកំពង់ឆ្នាំងមាននិស្សិតចំនួន៦៥ នាក់

៣-ខេត្តពោធិ៍សាត់ មាននិស្សិតចំនួន ៨៥ នាក់

៤-ខេត្តបាត់ដំបងមាននិស្សិតចំនួន ៣៥ នាក់

៥-ក្រុងប៉ៃលិន មាននិស្សិតចំនួន ១០ នាក់

៦-ខេត្តបន្ទាយមានជ័យ មាននិស្សិតចំនួន ២០ នាក់

៧-ខេត្តសៀមរាប មាននិស្សិតចំនួន ៨៣ នាក់

៨-ខេត្តស្វាយរៀង មាននិស្សិតចំនួន ៨៥ នាក់

៩-ខេត្តកំពត  មាននិស្សិតចំនួន ២០០ នាក់ ។

១០-ខេត្តកំពង់ចាម មាននិស្សិតចំនួន ៩៥ ៩២ នាក់

## III-ផ្នែកសង្គមកិច្ច និង ការអភិវឌ្ឍន៍:

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានប្រវាស់មេគោនៅខេត្តពោធិ៍សាត់ ដែលមានរូបភាពផ្ទាល់ដូចខាងក្រោម ៖

អង្គការបានប្រវាស់មេគោចំនួន១ក្បាលទៅ អោយលោកគ្រូ មឿង សាម៉េត នៅភូមិថ្មលប់បំបែក ឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ មេគោនេះ មានផ្ទៃពោះចំនួន៦ខែ ហើយ ។





អង្គការបានប្រវាស់មេគោចំនួន១ក្បាលទៅ អោយលោកប៉ាង សេរីភាព ដែលរស់នៅ ភូមិទួលគ្រោះ ឃុំចំរើនផល ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ មេគោនេះបានកើតកូនមេ១ក្បាល អាយុ៥ខែ។ ហើយកូនគោនេះ ជាចំណែករបស់អង្គការគឺភាគី(ក) ។

អង្គការបានប្រវាស់មេគោ១ក្បាលទៅអោយ លោក ពូ រៀម រស់នៅភូមិក្រហស្តក្បាល ឃុំរកា ស្រុកក្រវាញ ខេត្តពោធិ៍សាត់ ។ មេគោនេះកើតបានកូនមេ១អាយុ៨ខែ ហើយ។ កូនគោនេះជាចំណែករបស់អង្គការគឺភាគី(ក) ។





អង្គការបានប្រវាស់គោទៅអោយ លោកយាយ កោះ រៀង ដែលរស់នៅភូមិ ព្រៃស្នាច់ ឃុំរកា ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់។ មេគោនេះមិនទាន់មានទំងន់នៅឡើយទេ។



អង្គការបានប្រវាស់មេគោអោយទៅ ស្ត្រីមេម៉ាយ ឈ្មោះ ទៀង ហៀង រស់នៅភូមិព្រៃស្នាច់ ឃុំរកា ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ។ មេគោនេះមានកូនឈ្មោល១អាយុ៥ខែ។ ហើយនេះជារបស់អង្គការ



អង្គការបានប្រវាស់មេគោទៅអោយ ឈ្មោះ សេង ថានា នៅភូមិប្រឡាយធំ ឃុំវាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។ មេនេះមិនទាន់មានផ្ទៃពោះទេ ។



អង្គការបានប្រវាស់មេគោអោយទៅ លោក ចៅ ង៉ែត នៅភូមិថ្មី ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។ មេគោងាប់នៅសល់កូន ។



អង្គបានប្រវាស់មេគោទៅអោយ ឈ្មោះ សន ម៉ៅ នៅភូមិថ្កូលបំបែក ឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ កូនមេ អាយុ១ខែ

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទ បានចុះទៅដើម្បីចែករទេះជនពិការ ដល់អ្នកពិការចំនួន ២ នាក់នៅក្នុងស្រុកឈូក ខេត្តកំពត ដែលមានវត្តមានលោកប្រធានមន្ទីរការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ស្រុកឈូក លោកមេឃុំក្រាំងស្បូវ និងលោកគ្រូគង្វាលប្រចាំនៅព្រះវិហារឈើទាល ស្រុកឈូក អញ្ជើញចូលរួមក្នុងការប្រគល់នោះផងដែរ ។

ខាងក្រោមនេះជាសកម្មភាពដែលនាយកអង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទបានប្រគល់ជូន៖

១-លោក ឡុង ឆៃ ភេទ ប្រុស អាយុ ៤០ ឆ្នាំ

ភូមិ សត្វពង ឃុំ សត្វពង ស្រុក ឈូក ខេត្ត កំពត ។

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិបានប្រគល់រទេះជនពិការ១គ្រឿងអោយទៅ លោកយាយ តូច ហ៊ិន អាយុ៨៧ ឆ្នាំ ត្រូវជាម្តាយលោកគ្រូ យង់ សុត សព្វថ្ងៃរស់នៅ ផ្ទះលេខ៣៦OB ផ្លូវ ៦១BT ភូមិត្នោតជ្រុំ សង្កាត់ បឹងទំពុន ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ។



លោកយាយ តូច ហ៊ិន បានថ្លែងអំណរគុណ ដល់អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទ ដែលបាន ផ្តល់កៅអីនេះមកគាត់



នេះជារូបភាពទាំងស្រុងរបស់រទេះសំរាប់ជនពិការ ដែលស្ទប់១ផងដែរ ។



រូបភាពនេះដែលមានបិតផ្លាករបស់ អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ



លោកទូច ប៊ុនសឿម ជានាយកនៃអង្គការ កិច្ចការ ខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ ប្រចាំនៅកម្ពុជាបានបិតផ្លាកអំណោយរបស់អង្គការភ្ជាប់ ជាមួយរទេះជនពិការ ។



លោក ទូច ប៊ុនសឿម បានថតរួមគ្នាជាមួយ
ក្រុមគ្រួសាររបស់លោក យាយ តូច ហ៊ិន



លោកយាយមានចិត្តរីករាយជាខ្លាំង ដល់ម្ចាស់
ជំនួយដែលបានយកចិត្តទុកដាក់ដល់ជនពិការ
ក្រីក្រ ដូច្នេះសូមអោយម្ចាស់ជំនួយទាំងអស់
បានប្រកបដោយសេចក្តីសុខសាន្តក្នុងព្រះ
គ្រីស្ទជាអម្ចាស់ ។



ក្រុមគ្រួសារលោកយាយមានចិត្ត សប្បាយ
រីករាយជាខ្លាំង ដែល អង្គការកិច្ចការខ្មែរ
បំរើព្រះគ្រីស្ទអន្តរជាតិ បានជួយរទេះនេះ
មកម្តាយគាត់ ដែល ធ្វើអោយលោក យាយ
អាចទៅណាមកណាបានស្រួលជាងមុន ។
សូមអោយអង្គការបានរីកចំរើនតទៅមុខ
ទៀតការក្នុងការជួយដល់អ្នកក្រីក្រ ។
ពីព្រោះប្រទេសខ្មែរមានចាស់ជរាពិការនិង
អ្នកពិការច្រើនណាស់

បន្ទាប់មកលោក ទូច ប៊ុនសឿម បានសំណេះសំណាល ជាមួយក្រុមគ្រួសារ លោកយាយ តូច ហ៊ិន ហើយបានពន្យល់ប្រាប់អំពីការងាររបស់អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិបានធ្វើ និងពេល វេលាដែល អង្គការនេះបានចាប់ផ្តើម។ ប៉ុន្តែប្រពន្ធរបស់លោកគ្រូ ខៀវ វណ្ណាឡុង បាននិយាយថា ខ្ញុំមិន ដែលឮ ឈ្មោះរបស់អង្គការនេះទេ ទើបតែបានឮនៅពេលនេះឯង នៅពេលដែលបានឮអង្គការនេះធ្វើបានច្រើនណាស់ទាំងផ្នែកសាងសង់ផ្នែកហ្វឹកហ្វឺនដល់គ្រូគង្វាល និងអ្នកដឹកនាំ និងទាំងការជួយដល់ សហគមន៍ទៀត នោះជាប្រសើរណាស់ ។

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទបានជួយថវិកាចំនួន $៣៣០ ដល់លោក សូផុន ជានីញ៉ែល ជានិស្សិត ក្រីក្រអោយបានរៀននៅសកលវិទ្យាល័យប៊ីលប្រាយ ជាបន្តទៀត ដែលសព្វផ្នែក អភិវឌ្ឍន៍គំរោង និងកម្មវិធី។



អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទបានជួយឧបត្ថម្ភជាថវិកាចំនួន$៣៣០ ក្នុងរយៈពេល ៣ខែ ជាបន្តទៀត ដោយចាប់គិតពីខែមករា ដល់ មិនា ឆ្នាំ២០០៧ ដល់សិស្សក្រីក្រចំនួន ១១នាក់ ដែលម្នាក់ៗទទួលបាន $១០ក្នុង១ខែ ដើម្បីចំណាយលើការសិក្សារបស់ខ្លួន នៅខេត្តកំពត ដែលបានរាយនាមដូចខាង ក្រោមនេះ៖





ភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៧

អ្នកធ្វើរបាយការណ៍



ទូច ប៊ុនសឿម